**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤៦៦-៩៧

**<u>អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ ភ្នំពេញ</u>**

**<u>ជម្រាបមក</u>**

**លោកព្រះរាជអាជ្ញា ប្រចាំតុលាការ ខេត្តស្វាយរៀង**

**<u>កម្មវត្ថុ:</u>** ការផ្តល់យោបល់អំពីករណីនគរបាលដោះលែងជនអន្តោប្រវេសន៍ ។

**<u>យោង:</u>** លិខិតរបស់លោក លេខ ២១២ អ.ក ចុះថ្ងៃទី០១-០៨-៩៧ ។

តាមលិខិតរាយការណ៍យោងខាងលើ លោកបានទទួលដំណឹងថា នគរបាលខេត្តស្វាយរៀងចាប់បានជនអន្តោប្រវេសន៍ចិនដីគោកចំនួន៤នាក់ រថយន្តមួយគ្រឿង នឹងអ្នកបើកបរម្នាក់ កាលពីថ្ងៃទី១៩-០៧-៩៧ ប៉ុន្តែលោកស្នងការនគរបាលខេត្តបានដោះលែងទៅវិញទាំងអស់ដោយគ្មានបញ្ជូនខ្លួនជនល្មើស វត្ថុតាង នឹងកំណត់ហេតុមកអយ្យការសោះ ។

ខ្ញុំសូមជម្រាបលោកវិញថា តាមបញ្ញត្តិមាត្រា ៣៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ថ្ងៃ២៨ មករា ១៩៩៣ ស្នងការនគរបាល ឬអធិការនគរបាល ឬប្រធាន ឬនាយការិយាល័យនគរបាលខេត្ត កាលណាបំពេញតួនាទីដើម្បីពិនិត្យ ឬស្រាវជ្រាវអំពើល្មើស និងបទល្មើសព្រហ្មទណ្ឌណាមួយទាំងបទល្មើសព្រហ្មទណ្ឌចែងក្នុងមាត្រា ២៩,៣២ នៃព្រះរាជក្រមលេខ ០៥៨.ស ៩៤ ចុះថ្ងៃទី២២-០៩-៩៤នោះ គាត់បំពេញតួនទីជាមន្ត្រីនគរបាលយុត្តិធម៌ហើយស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ព្រះរាជអាជ្ញា ប៉ុន្តែពុំមែនក្រោមត្រឡាបញ្ជីទេ ។ ដូច្នេះលោកព្រះរាជអាជ្ញាក្នុងនាមជាអ្នកត្រូវចេញបញ្ជាផ្ទាល់លោកអាចចាត់ការតាមន័យនេះតទៅ ។ បើលោកចាត់ការហើយៗយល់ឃើញថា គ្មានការគោរពបញ្ជារបៀបណាមួយ លោកអាចរាយការណ៍ទៅ ឯកឧត្តមអភិបាលខេត្ត ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងមកខ្ញុំអគ្គព្រះរាជអាជ្ញាប្រចាំសាលាឧទ្ធរណ៍ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៧

**អគ្គរដ្ឋអាជ្ញា**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌ ដើម្បីជ្រាប

**ហង់រ៉ូ រ៉ាគេន**